HONEYCOMB 2/1 (January 2001): 26–31



*Ian WEBBER*

# Intercession

**An eyewitness tells Luke what he recalls of the Last Supper**

"It was a night of mixed emotions I have to tell you, Luke—that Passover Meal. First of course there was a note of celebration in this annual reminder of Yahweh's Great Deliverance of us His people.[1] But there was also a sense of unease in that upper room. It flowed back and forth among those who were gathered there, and kept surfacing. I knew Jesus was aware of it, too. Undoubtedly it was brought on to some extent by the tensions that were always simmering just below the surface in Israel. We knew we were slaves again—not in Egypt this time, but here in our own land. Not under Pharaoh, but now under Caesar.

"Our own personal well-being was also threatened. Pressure was building among the Temple leaders to squash the Master's influence. Much had occurred, even in just the last few weeks, that seemed to point to something quite dangerous. I've

---

[1]Exodus 3:7.

already told you about some of these things, you'll remember, Luke.[2]

"There was something else too—an argumentativeness that was disturbing our time. In the squabbling and boasting in which we were caught up, our fellowship had suddenly become fragile. Jesus quite properly rebuked us, and we were all chastened—but the sour note lingered around the table. It was a somewhat 'uneasy truce' for a few of us who wanted to continue pushing our own claims to be considered 'the greatest.' I have to say that Peter was in this group! But so, I'm ashamed to admit, was I.

"Then we come to what is for me the most disturbing element of the entire meal. Simon was still urging *his* claim to the top spot in the list. He had stopped listening to what Jesus was saying. He was deaf to the Master's words—insensitive to the Lord's exhortation. He was ignoring Him. Then Jesus brings Peter, and the rest of us, up with a jolt. "Simon! Simon!" He doesn't shout, or even raise His voice. But we *all* hear him. The whole room is suddenly very, very still.

"Simon often talks more than he listens, I've noticed. But now, with everyone else around the table, he is most certainly in the 'listening mode.' And the chilling announcement falls from Jesus' lips that we are and will be in great spiritual danger—Satan's testing ('assault' might be a better term) is imminent!

"What is so terribly frightening is that Satan can challenge God, and that it will be up to us to stay faithful. Perhaps even more unnerving is that the main responsibility for holding us faithful will rest on Peter! Peter, for goodness' sake! Well, that certainly sobered him, I remember. The one thing that provided a glimmer of hope (a strong note of hope, actually) was Jesus' assurance that He had already interceded. Every single one of us knew that He would continue to do so.

"My throat was dry. I reached across to take a sip of wine. In my mind's eye I saw the winnower at work—the grain scooped

---

[2]Luke 22:15; 21:12; 20:46a; 19:41; 17:24; 14:24; 13:31, 17; etc.

up and thrown into the air, and a strong wind separating forever the chaff from the grain. . . ."

That is how I told Dr. Luke my version of what that last supper was like, when he was researching for his "orderly account." It is as vivid to me now as it was that night so long ago.

## A great promise

In this article I want to focus on Jesus' words to Peter (after He had gotten Peter's attention) and to the rest of us as well. Peter—who had lapsed into a "Simon" during the meal—is in effect designated the leader for at least the coming crisis. The ugly infighting prior to Jesus' rebuke was both so unnecessary and so demeaning. The Lord assured His disciples that He had interceded for Peter. They surely understood that He would continue to do so, and that by implication they too were included in this. For Peter specifically, His prayer of intercession was for "The Rock."

All this was surely of great encouragement to them (as it is for us) even though they all faltered shortly thereafter (as we often do). And of course the wonderful promise enshrined in Scripture[3] remains certain for us that we might be courageous (given fresh 'heart') in the face of every trial, every temptation, every problem.

## Partnership

We often say, "I'll pray for you." At times that can be something of a "throw-away line"—a phrase of little substance and not much intentionality. However it is that we *say* the statement, what it needs to *mean* is, "I promise to allocate specific time(s) when I will pray earnestly for you in the matter of . . . ."

It is the same in Khmer as in English, I suppose, that the meanings of words change over time. This is no surprise, and we ought to use words in the way that everyone else uses them. However, it is equally important on occasion for us to go back to what words *originally* meant. For example, to "comfort" is often

---

[3]Hebrews 7:24a, 25b.

used nowadays to mean something like giving a person a brief pat on the head or a hand on the arm and saying, "There, there; never mind. You'll be OK!" and then walking away. So it has a *soft* meaning. Originally it meant to *do* something that would be genuinely *empowering* for a person. The other became *strong* (Latin: *fortis*) by our being *with* (Latin: *com*) him or her in some positive, purposeful, and supportive way. It is an ongoing, unflagging thing. The *com-fort-er* doesn't lose interest after a few minutes; the *com-fort-er* doesn't say or do something once and then withdraw; the *com-fort-er* doesn't give up.

And inevitably a *com-fort-er* is an intercessor. So what is the original meaning of intercession? And what are its characteristics and purpose?

## Context and content

Basically, interceding is *acting between and on behalf of people*. That means acting between and on behalf of their situations, conflicts, difficulties, relationships, meetings. It is usually a case of assisting, facilitating, linking, *connecting* people—being a go-between for them. Sometimes it means doing for people what they cannot at the time do for themselves. It means to act on behalf of one or more parties for the sake of justice or mercy or healing or reconciliation or forgiveness.

It can also mean acting to *dis-connect*! For example an intercessor will sometimes act to *prevent* a crisis, danger, pain, stress, depression, or fear.

Different contexts define the content and the nature of our interceding. And the above cluster of descriptions implies that it is not something we do casually or off-handedly. It is much more than, "Let's have a word [!] of prayer about. . . ." It is, and is meant to be, *sustained* work.

## Biblical contexts guide our thinking

When the purpose of our intercession is that of *connecting*, we will be taking people—in our minds—into the presence of God

and up to the throne of His grace, and *asking on their behalf* for something. We can intercede for others when we are physically with them, although much of our interceding is done in their absence.

In the days after Hannah's impassioned petition to the Lord for a son, it is surely possible that Eli interceded for her beyond what is highlighted in 1 Samuel 1:17 and 2:20.. Prayer is a key role for a priest—to intercede is part of his ministry. That, by the way, is true for us all. It is part of what is meant when we talk of the priesthood of *all* believers.

There are examples of intercession in Solomon's great prayer at the dedication of the Temple.[4] On the other hand there is *no* evidence in the Book of Jonah that the prophet made intercession for Nineveh. God is bigger than our interceding, of course, but Jonah "short-changed" himself by failing to intercede. Matthew's account of the storm[5] certainly sounds like a cry of urgent intercession for their comrades. It was surely an individual petition as well, we have to say.

When the purpose of our intercession in to *prevent links*, to *block connections*, then we plead with the Sovereign Lord on behalf of afflicted ones. We stand *against* those things that take hold of people and threaten their safety, or their sanity, or their ministry, or their health—whatever has the affect (or "intention") of dulling God's love, impeding God's grace, weakening someone's hope, or reducing their trust, joy, or faith.

## Summary

Intercession is a gift that is given to us, and a ministry that is stirred up within us. It is the "scenery" for God's "theater." It is—if we continue to use the imagery of theater—one of the "backdrops" for the drama of God's saving, healing, forgiving, enabling work. Our intercession is included as part of the Lord's processes that make up the work of God among people. It is one of

---

[4]See 1 Kings 8:30, 34, 38-39, 45, 49.
[5]Matt 8:25.

the tools by which God loosens the hold of a hard heart and an unbelieving spirit; by which He weakens sin's grip. It attacks fear and operates to take some of the deep pain out of the natural consequences of tragedy; psychological distress, emotional damage, mental anguish, relationship breakdown, etc. It is one of the great bulwarks against all such troubles.

So our intercession is an act of *great love.* When we engage in the priestly ministry of intercession we enter into a project that applies a spiritual balm—a gentle, soothing, healing ointment—to the heart, mind, body, soul, spirit of needy people.

សំណុំឯកឃ្មុំ ២/១ (មករា ២០០១): ៣២-៤១



# ការទូលអង្វរ

✲✲✲✲✲✲✲✲✲

អៀន ទីប័រ

## មានសាក្សីម្នាក់ បានប្រាប់មកលោក លូកា នូវអ្វីដែលគាត់នៅចាំបាននៅពេល អាហារល្ងាចចុងក្រោយ មុនពេលគេចាប់ព្រះយេស៊ូ

"យប់នោះគឺជាយប់ ដែលប្រកបដោយអារម្មណ៍ច្របូកច្របល់មែនទែន ខ្ញុំសូមជំរាបលោកឲ្យដឹងទៅ លោកលូកា គឺជាយប់ដែលទទួលទានអាហារនៅពេលបុណ្យរំលង ។ ចាប់ផ្តើមដំបូងទៅមានកំណត់ហេតុពីពិធីបុណ្យនេះជាប្រចាំឆ្នាំ រំលឹកពីការដែលព្រះអង្គដោះរាស្ត្ររបស់ព្រះអង្គឲ្យរួចពីគ្រោះកាចអាក្រក់នោះ[១] ។ ប៉ុន្តែមានការចម្លែកមួយនៅបន្ទប់ជាន់លើ ។ គឺការនេះកើតឡើងក្នុងចំណោមអ្នក ដែលកំពុងប្រជុំជាមួយគ្នាហើយនិងការនោះឯងចេះតែលេចធ្លោចេញមក ។ ខ្ញុំបានដឹងថាព្រះយេស៊ូក៏ជ្រាបពីការនេះដែរ ។ ដោយឥតសង្ស័យគឺលេចធ្លោឡើងដោយមានភាពតានតឹង ដែលតែងតែហៀបនឹងពុះកញ្ជ្រោលឡើង នៅក្នុងប្រទេសអ៊ីស្រាអែល ។ យើងបានដឹងថាយើងក្លាយជាទាសករម្តងទៀត តែម្តងនេះមិនមែននៅ ប្រទេសអេស៊ីពទេ គឺនៅនឹងទឹកដីរបស់យើង

---

[១] និក្ខមនំ ៣:៧

ផ្ទាល់តែម្តង ។ មិនមែននៅក្រោមនឹមរបស់ព្រះចៅផារ៉ោនទេ តែនៅក្រោមព្រះចៅអធិរាជ សេសា វិញ ។

"សុខមាលភាពរបស់យើងផ្ទាល់ ក៏ទទួលរងនូវការគំរាមដែរ" ។ ភាពតានតឹងកាន់តែកើនឡើង ក្នុងចំណោមអ្នកដឹកនាំក្នុងព្រះវិហារ ដើម្បីរំលាយឥទ្ធិពល របស់ចៅហ្វាយនាយ ។ មានរឿងជាច្រើនកើតឡើង គឺគ្រាន់តែពីរបីអាទិត្យមុនតែប៉ុណ្ណោះ ដែលហាក់បីដូចជាកំពុងចង្អុលបង្ហាញឲ្យឃើញថាគឺជាគ្រោះថ្នាក់ធំណាស់ ។ ខ្ញុំបានប្រាប់លោករួចមកហើយ អំពីរឿងរ៉ាវខ្លះលោកនឹងចាំបាន លោក លូកា[២] ។

"មានរឿងរ៉ាវខ្លះទៀតដែរ គឺជាជម្លោះ ដែលធ្វើឲ្យយើងមានអារម្មណ៍មិនស្រួល នៅក្នុងសម័យយើងនេះ ។ យើងបានជាប់ជំពាក់ក្នុងការឈ្លោះទាស់ទែងគ្នា ក្នុងរឿងឥតបានការ និង ក្នុងសេចក្តីអំនួតនោះ ធ្វើឲ្យការប្រកបទាក់ទងរបស់យើង ក្លាយទៅជាភាពងាយស្រួលក្នុងការបែកបាក់គ្នា ។ ព្រះយេស៊ូបានបន្ទោសយើងយ៉ាងខ្លាំង ហើយយើងទាំងអស់ក៏ដឹងខ្លួនដែរចំពោះរឿងនេះ ប៉ុន្តែភាពជូរចត់ នោះបីដូចជាមិននៅឆ្ងាយពីជុំវិញតុនោះឡើយ ។ គឺជាការដែល "ពិបាកចរចារគ្នាបន្តិច" ក្នុងចំណោមយើងពីរបីនាក់ ដែលចង់បន្តធ្វើឲ្យការអះអាងរបស់យើងមាន គេចាប់អារម្មណ៍ថា "ធំជាងគេបំផុត" ។ ខ្ញុំត្រូវតែនិយាយថាអ្នកគិតបែបនោះគឺជា ពេត្រុស ដែលនៅក្នុងក្រុមនេះ! ប៉ុន្តែខ្ញុំអៀនណាស់ក្នុងការទទួលស្គាល់ការនោះ ព្រោះខ្ញុំក៏ដូចគ្នាដែរ ។

"បន្ទាប់មក យើងក៏មកដល់កន្លែងមួយ ដែលខ្ញុំធ្វើឲ្យមានការជ្រួលច្របល់យ៉ាងខ្លាំងក្នុងពេលរួមតុអាហារជាមួយគ្នានោះ ។ ស៊ីម៉ូន គឺនៅតែអះអាងថា គាត់គួរតែបានឡើងដល់កិត្តិជាងគេជាងឯង ។ គាត់ឈប់ស្តាប់នូវអ្វី ដែលព្រះយេស៊ូ មានបន្ទូលទៀតហើយ ។ គាត់ក្លាយទៅ

---

[២] *លូកា ២២:១៥; ២១:១២; ២០:៤៦; ១៩:៤១; ១៧:២៤; ១៤:២៤; ១៣:៣១, ១៧ ជាដើម*

ជាមនុស្សមានត្រចៀកធ្ងន់ លែងស្តាប់ដល់ការដាស់តឿនរបស់ព្រះជាម្ចាស់ ។ គាត់ធ្វើដូចជាមិនដឹងមិនឮ ចំពោះព្រះអង្គ ។ បន្ទាប់មក ព្រះយេស៊ូបាននាំឲ្យពេត្រុស និង យើងគ្រប់គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ "ស៊ីម៉ូន! ស៊ីម៉ូន" ព្រះអង្គមិនបានស្រែក ឬ ក៏មិនលើកព្រះសូរសៀងរបស់ព្រះអង្គឡើយ ។ ប៉ុន្តែយើងទាំងអស់គ្នាបានស្តាប់ឮព្រះអង្គមានបន្ទូល ។ រំពេចនោះ បន្ទប់ទាំងមូលត្រូវស្ងាត់ឈឹង គ្មាននរណាម្នាក់ឮមាត់ឡើយ ។

"ស៊ីម៉ូន ជាទូទៅជាមនុស្សនិយាយច្រើនជាងស្តាប់ ខ្ញុំបានសង្កេតឃើញបែបនោះមែន ។ ប៉ុន្តែឥឡូវរួមទាំងមនុស្សគ្រប់គ្នាឯទៀត ដែលនៅជុំវិញតុ គឺគាត់ជាអ្នកដែល "ខំប្រឹងស្តាប់" ជាងគេបំផុត ។ ការប្រកាសជូនដំណឹងមួយគួរព្រឺឆ្អឹងខ្នង បានធ្លាយចេញពីបបូរមាត់របស់ព្រះយេស៊ូ ដែលថា យើងទាំងអស់គ្នានឹង ស្ថិតនៅក្នុងបញ្ហាគ្រោះថ្នាក់យ៉ាងសម្បើមផ្នែកខាងវិញ្ញាណ គឺ ដោយសារការល្បងលរបស់សាតាំង («ការវាយប្រហារ» ប្រហែលជាពាក្យ ដែលគួរប្រើប្រសើរជាងនេះ) បំរុងនឹងកើតឡើង ក្នុងពេលឆាប់ៗនេះ! ។

"អ្វីដែលគួរភ័យខ្លាចបំផុតនោះគឺថា សាតាំងអាចបបួលព្រះជាម្ចាស់ ដើម្បីតតាំងគ្នា ហើយនិងការនោះ គឺស្រេចតែនៅលើយើងក្នុងការនៅតែស្មោះស្ម័គ្រ នឹងព្រះអង្គ ឬ របូតពីព្រះអង្គនោះ ។ ប្រហែលរឹតតែធ្វើឲ្យបាត់បង់សេចក្តីក្លាហានថែមទៀត គឺថាការទទួលខុសត្រូវសំខាន់សំរាប់ជួយទប់យើងឲ្យនៅមានជំនឿមាំ នោះនឹងធ្លាក់មកលើ ពេត្រុស! ដោយយល់តាមសេចក្តីសប្បុរសនោះ គឺពេត្រុស អ្ហ៎ មែនហើយតាមដែលខ្ញុំចាំបាន តាមពិតទៅការនោះធ្វើឲ្យគាត់គិតពិចារណាយ៉ាងខ្លាំង ។ ការមួយនោះ ដែលធ្វើឲ្យមានក្តីសង្ឃឹម (តាមពិតទៅជាក្តីសង្ឃឹមយ៉ាងខ្លាំង ) គឺព្រះយេស៊ូ ។ ការអះអាងរបស់ព្រះយេស៊ូ ដែលថាព្រះអង្គ

បាន ទូលអង្វរដល់ព្រះបិតាជំនួសយើងរួចហើយ ។ យើងម្នាក់ៗបានដឹងថា ព្រះអង្គនឹងបន្តធ្វើការទូលអង្វរបែបនោះតទៅទៀត ។

"បំពង់ករបស់ខ្ញុំស្ងួតចែស ខ្ញុំក៏ឈោងទៅរកស្រាមកក្រេបមួយចិប ។ នៅក្នុងគំនិតរបស់ខ្ញុំ ខ្ញុំមើលឃើញអ្នករោយស្រូវកំពុងធ្វើការ គឺថាគ្រាប់ស្រូវ កំពុងតែចូកហើយ រោយនៅកណ្តាលខ្យល់កំពុងបក់ ហើយនិងខ្យល់ដែលកំពុងបក់យ៉ាងខ្លាំងនោះ បានញែកអង្កាមចេញពីគ្រាប់ស្រូវដ៏ល្អនោះ ចេញពីគ្នារហូត . . . . ." ។

នោះឯងគឺជាអ្វីដែលខ្ញុំបានប្រាប់ដល់លោកវេជ្ជបណ្ឌិត លូកា ស្តីពីដំណើររឿងរ៉ាវ ដែលខ្ញុំសង្កេតឃើញនៅវេលាអាហារពេលយប់ចុងក្រោយនោះ! នៅពេលដែលគាត់កំពុងតែស្រាវជ្រាវរៀបចំសាច់រឿងនេះ"តាមលំដាប់លំដោយ" ក្នុងសំណេររបស់គាត់ ។ រឿងនោះហាក់បីដូចកំពុងស្ថិតនៅរស់រវើកចំពោះមុខខ្ញុំ ឥឡូវនេះ ថ្វីដ្បិតតែយប់នោះកន្លងទៅយូរណាស់ហើយក៏ដោយ ។

## សេចក្តីសន្យាដ៏ធំអស្ចារ្យ

នៅក្នុងអត្ថបទនេះ ខ្ញុំចង់ផ្តោតសំខាន់លើ ព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលព្រះអង្គមានបន្ទូលទៅកាន់ ពេត្រុស (បន្ទាប់ពីព្រះអង្គបានដាស់ស្មារតីរបស់ពេត្រុសឲ្យដឹង) ហើយមានបន្ទូលទៅកាន់យើងទាំងអស់គ្នាដែរ ។ ពេត្រុស ដែលឈ្មោះនេះមិនបានយកមកប្រើ បែរជាប្រើ "ស៊ីម៉ូន វិញ នៅក្នុងពេលទទួលទានអាហារនោះ គឺមានឥទ្ធិពលចំពោះអ្នកដឹកនាំ ដែលបានដៅទុកជាស្រេច សំរាប់វិបត្តិ ដែលនឹងបំរុងកើតនៅថ្ងៃខាងមុខនោះ ។ ភាពមិនចុះសម្រុងគ្នា ដែលកើតឡើងមុនពេលព្រះយេស៊ូ ស្តីបន្ទោសនោះគឺជារឿងមិនសូវចាំបាច់ផង និង ជារឿងគួរបាត់បង់ភាពថ្លៃថ្នូរថែមទៀតផង ។ ព្រះអម្ចាស់បានធានាអះអាងចំពោះសិស្សរបស់ព្រះអង្គថា ព្រះអង្គបានទូលអង្វរជំនួសពេត្រុសរួច

ហើយ ។ ពួកគេទាំងអស់ពិតជាបានយល់ថា ព្រះអង្គនឹងបន្តធ្វើការទូលអង្វរនោះជាបន្តទៀត និង ដោយការកាត់ស្មាននោះ ពួកគេក៏នឹងបានទទួលការទូលអង្វរជំនួសនេះដែរ ។ សេចក្តីអធិស្ឋាននៃការទូលអង្វរគឺសំរាប់ "ថ្មដា" គឺចំលើ ពេត្រុស តែម្តង ។

តាមពិតទៅគ្រប់ការទាំងអស់ គឺជាការលើកទឹកចិត្តយ៉ាងសម្បើម (ក៏ដូចគ្នាសំរាប់យើងដែរ) ទោះបីជាការលើកទឹកចិត្តនោះ ត្រូវធ្លាក់ចុះខ្សោយ មិនយូរប៉ុន្មានបន្ទាប់មកនោះក៏ដោយចុះ (ដូចដែលយើងជារឿយៗធ្លាប់តែមានការបែបនោះ ) ។ តាមពិតទៅសេចក្តីសន្យាដ៏អស្ចារ្យដែលបានតម្កល់ទុកក្នុងបទគម្ពីរ[៣] ដែលនៅតែមានយ៉ាងពិតជាក់សំរាប់យើង ដែលធ្វើឲ្យយើងអាចទទួលនូវការលើកទឹកចិត្ត (ផ្តល់ឲ្យមានដួងចិត្តស្រស់ថ្លា) នៅចំពោះការល្បងលគ្រប់ទាំង សេចក្តីល្បួងនានា និង បញ្ហាទាំងឡាយនោះ ។

## ភាពជាដៃគូ

យើងតែងនិយាយថា "ខ្ញុំនឹងអធិស្ឋានឲ្យអ្នក" ។ ជួនកាលពាក្យនោះអាចគ្រាន់តែជាពាក្យដែល "ថាឲ្យតែរួចពីមាត់" គឺជាឃ្លាដែលមានទម្ងន់តិចតួច និងមិនមានការតាំងចិត្តច្រើនប៉ុន្មានទេ ។ ទោះបីជាយ៉ាងណាក៏ដោយ គឺជាការដែលយើងនិយាយ បើពិតជាមានន័យដូចនោះមែនគឺ "ខ្ញុំសន្យានឹងញែកពេលជាក់លាក់ណាមួយ ដែលខ្ញុំនឹងអធិស្ឋានដោយយកចិត្តទុកដាក់សំរាប់អ្នក មិនថាមានរឿងអ្វីកើតឡើងឡើយ . . . ." ។

ខ្ញុំគិតថា គឺដូចគ្នាទាំងនៅក្នុងភាសាខ្មែរ ក៏ដូចគ្នា និង ភាសាអង់គ្លេសដែរ ដែលថាអត្ថន័យនៃពាក្យ គឺមានការប្រួលប្រែដល់ពេលយូរទៅ ។ គ្មានអ្វី ដែលគួរឲ្យភ្ញាក់ផ្អើលឡើយ យើងគួរតែប្រើពាក្យទាំងឡាយណា ដែលគេគ្រប់គ្នាប្រើ ។ ទោះបីជាយ៉ាងណាក៏ដោយ គឺជា

---

[៣] *ហេព្រើ ៧:២៤ ដើម១ , ២៥ចុង១*

ការសំខាន់ក្នុងពេលខ្លះសំរាប់យើង ដែល ត្រូវស្រាវជ្រាវរកអត្ថន័យដើមរបស់ពាក្យទាំងនោះ ។ ឧទាហរណ៍ពាក្យថា "ផ្តល់ ភាពកក់ក្តៅ" គឺជាទូទៅ ដែលគេយកពាក្យនេះមកប្រើសព្វថ្ងៃនេះ គឺមានន័យដូចជាការផ្តល់ឲ្យមនុស្សម្នាក់នោះ នូវភាពធូរស្រាល ដោយការអង្អែលក្បាលថ្នមៗ ឬ ការគោះលើដៃថ្នមៗ ហើយនិយាយថា "អត់អីទេ! អត់អីទេ! កុំព្រួយអី!" ហើយបន្ទាប់មកក៏ដើរចេញទៅបាត់ ។ ដូច្នោះគឺមានន័យស្រាលមែនទែន ។ ពាក្យនេះជាអត្ថន័យដើម គឺធ្វើអ្វីមួយ ដែលពិតជាផ្តល់បុទ្ធានុភាពដល់មនុស្សណាម្នាក់ ។ អត្ថន័យ មួយទៀតមានន័យថា រឹងមាំ (ដែលក្លាយមកពីពាក្យ ឡាតាំង: **fortis** ) បូកជាមួយរូបកាយរបស់យើង ជាមួយ (ពាក្យឡាតាំង: **Com** ) គាត់ ឬ នាងក្នុង ចំណុចវិជ្ជមានណាមួយ ដោយមានបំណងច្បាស់លាស់ និង ដោយប្រើក្នុងរបៀបមួយ ដែលគាំទ្រក្នុងការអ្វីមួយ ។ ការនេះគឺជាការមួយដែលបន្តទៅមុខរហូត មិនជាការដែលត្រូវចុះខ្សោយទៅៗនោះទេ ។ អ្នកផ្តល់ភាពកក់ក្តៅ ឬ អ្នកលើកទឹកចិត្ត មិនមែនចាប់អារម្មណ៍តែមួយភ្លែតឡើយ គឺមិនមែនគ្រាន់តែនិយាយ និង ធ្វើការតែម្តង ហើយដកខ្លួនចេញនោះឡើយ គឺមិនត្រូវបោះបង់ចោលឡើយ ។

ហើយម្យ៉ាងទៀត អ្នកកំសាន្តចិត្តឬអ្នកលើកទឹកចិត្ត មិនអាចគេចរួចពីនាទីជាអ្នកទូលអង្វរនោះឡើយ ។ ចុះតើអត្ថន័យដើមនៃពាក្យទូលអង្វរជាអ្វីទៅ? តើអ្វីទៅជាលក្ខណៈ និង ជាគោលដៅរបស់ពាក្យនោះ?

## បរិបទ និង មាតិកា

និយាយយ៉ាងងាយស្តាប់ទៅ ការទូលអង្វរគឺជាការឈរនៅកណ្តាល និង ឈរជាតំណាងឲ្យមនុស្ស ។ ការនោះមានន័យថា ការឈរនៅកណ្តាល និង ឈរជាតំណាងស្ថានការណ៍ បញ្ហាទំនាស់ ការលំបាកទំនាក់ទំនង ការជួបប្រជុំរបស់គេ ។ ពាក្យនេះតាមធម្មតា ជាករណីជួយធ្វើ

ជួយសម្រួល ជួយភ្ជាប់មនុស្សនិងព្រះ តាមរយៈសន្ធានការី ដែលធ្វើការជំនួសឲ្យពួកគេ ។

ជួនកាលគឺមានន័យថា ការធ្វើការអ្វីជំនួសមនុស្សទាំងឡាយណាដែល គេមិនអាចធ្វើកើត នៅក្នុងពេលនោះ គឺធ្វើជំនួសពួកគេ ។ គឺមានន័យថាធ្វើអ្វីមួយ ជំនួសក្នុងនាមជាតំណាងឲ្យក្រុមមួយ ឬក្រុមច្រើន ដើម្បីបុព្វហេតុនៃយុត្តិធម៌ ឬ ដោយសេចក្តីមេត្តាករុណា ឬ ដោយការប្រោសឲ្យជា ឬ ការផ្សះផ្សា ឬ ការ អត់ទោសបាប ។

ពាក្យនេះអាចមានន័យថា ធ្វើការផ្តាច់ចេញ! ឧទាហរណ៍ អ្នកទូលអង្វរជំនួស ជួនកាលមានមុខងារការពារវិបត្តិ គ្រោះថ្នាក់ ការឈឺចាប់ ភាពតានតឹង ការធ្លាក់ទឹកចិត្ត ឬ ការភ័យខ្លាចមិនឲ្យមានការទាំងអស់នេះកើតឡើង ។

បរិបទផ្សេងៗកំណត់រកអត្ថន័យនូវខ្លឹមសារ និង និស្ស័យលក្ខណៈនៃការទូលអង្វររបស់យើង ។ ការពិពណ៌នាមួយចង្កោមខាងលើ បានបង្ហាញថា ការទូលអង្វរមិនមែនជាការដែលយូរៗម្តងយើងធ្វើ ឬធ្វើដោយចុងដៃចុងជើងនោះឡើយ ។ គឺមិនគ្រាន់តែថា "តោះយើងអធិស្ឋាន! ចំពោះរឿងនេះ . . . ប៉ុណ្ណោះទេ" គឺមានន័យថា ជាការងារមួយដែលយើងធ្វើដោយមាននិរន្តរភាពជានិច្ច ។

## គោលគំនិតនៅក្នុងព្រះគម្ពីរជួយគំនិតរបស់យើង

នៅពេលដែលគោលបំណងនៃការទូលអង្វររបស់យើង ដែលផ្តោតលើការតភ្ជាប់នោះ យើងនឹងគិតអំពីមនុស្ស នៅក្នុងគំនិតរបស់យើង ក្នុងការនាំគេឲ្យចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ និង នាំគេឲ្យចូលទៅក្នុងព្រះវត្តមាននៃ ព្រះជាម្ចាស់ និង ឡើងទៅដល់បល្ល័ង្កនៃព្រះគុណរបស់ព្រះអង្គ និង ទូលសុំជំនួសគេ ចំពោះការងារអ្វីមួយ ។ យើងអាចទូលអង្វរជំនួសអ្នកដទៃ នៅពេលណាដែលយើងនៅជាមួយ

គេដោយផ្ទាល់ ទោះបីជាការទូលអង្វររបស់យើង ធ្វើឡើងនៅពេលកំបាំងមុខរបស់អ្នកទាំងនោះក៏ដោយចុះ ។

នៅក្នុងសម័យបន្ទាប់ពីការទូលសុំយ៉ាងទទូចរបស់នាងហាណាដល់ព្រះអម្ចាស់ ដើម្បីសុំកូនប្រុសមួយ គឺពិតជាអាចទៅរួចដែរ ដែលថាអេលី បានទូលអង្វរជំនួសនាង លើសពីអ្វីដែលបានចែងយ៉ាងច្បាស់នៅក្នុងគម្ពីរ ១សាំយូអែល ១:១៧ និង ១សាំយូអែល ២:២០ ។ ការអធិស្ឋានគឺជាតួនាទីដ៏សំខាន់របស់សង្ឃ ទូលអង្វរគឺជាផ្នែកមួយ នៃព័ន្ធកិច្ចរបស់សង្ឃ ។ មែនហើយការនេះគឺជាការពិតសំរាប់យើងរាល់រូប ។ គឺមានន័យថាក្នុងនាមយើងជាអ្នកជឿរាល់រូបត្រូវមានផ្នែកដែលជាកិច្ចការរបស់សង្ឃនេះគ្រប់គ្នា ។

មានឧទាហរណ៍ជាច្រើន នៃការទូលអង្វរនៅក្នុងការអធិស្ឋានរបស់សាឡូម៉ូន ក្នុងការឧទ្ទិសថ្វាយព្រះវិហារដល់ព្រះជាម្ចាស់[៤] ។ ម្យ៉ាងទៀតគ្មានភស្តុតាងបង្ហាញនៅក្នុងកណ្ឌគម្ពីរយ៉ូណាសទេ ដែលថាហោរានេះ បានធ្វើការទូលអង្វរសំរាប់ទីក្រុងនីនីវេ ។ ព្រះជាម្ចាស់ ធំជាងការទូលអង្វររបស់យើង តាមពិតទៅយ៉ូណាស "បង្ហាញពីចំណុចខ្វះខាត" របស់គាត់ដោយមិនបានទូលអង្វរដល់ព្រះជាម្ចាស់ទេ ។ សាច់រឿងរបស់លោកម៉ាថាយ ស្តីពីខ្យល់ព្យុះ[៥] តាមពិតទៅប្រៀបដូចជា សម្រែកនៃការទូលអង្វរជាបន្ទាន់សំរាប់មិត្តសម្លាញ់របស់គេ ។ តាមពិតទៅគឺជាការទូលសូមផ្ទាល់ខ្លួនម្នាក់ៗផងដែរ បើតាមនិយាយឲ្យចំទៅ ។

នៅពេលគោលបំណង នៃការទូលអង្វររបស់យើងផ្តោតទៅក្នុងការផ្តាច់ចំណង គឺរាំងរាមិនឲ្យមានការតភ្ជាប់នោះ យើងទូលសូមដល់ព្រះជាម្ចាស់ ដោយឈរជាតំណាងឲ្យអ្នកដទៃ ដែលទទួលរងនូវការឈឺចាប់ ។ យើងឈរទាស់ទទឹង នឹងរឿងរ៉ាវទាំងឡាយ ដែលរារាំង និង

---

[៤] *សូមមើល ១ពង្សាវតាក្សត្រ ៨:៣០, ៣៤, ៣៨-៣៩, ៤៥, ៤៩ ។*

[៥] *ម៉ាថាយ ៨:២៥*

គំរាមកំហែងដល់សេចក្ដីសេចក្ដីសុខរបស់គេ ឬ ដល់សតិបញ្ញារបស់គេ ឬ ដល់ព័ន្ធកិច្ចរបស់គេ ឬ ដល់សុខភាពរបស់គេ អ្វីក៏ដោយដែលមានឥទ្ធិពល (ឬ "មានបំណង" ) ធ្វើឲ្យសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ វិលវល់ ដែលរាំងស្ទះដល់ព្រះគុណរបស់ព្រះជាម្ចាស់ ធ្វើឲ្យសេចក្ដីសង្ឃឹមចុះខ្សោយ ឬ ខ្វះការទុកចិត្ត ខ្វះអំណរ ឬ ក៏ខ្វះជំនឿ ។

## សង្ខេបឡើងវិញ

ការទូលអង្វរគឺជាអំណោយទាន ដែលព្រះជាម្ចាស់បានផ្ដល់មកឲ្យយើង និង ព័ន្ធកិច្ច ដែលធ្វើឲ្យយើងរំជួលចិត្តនោះ ។ គឺជា "ឆាកទស្សនីយភាព" សំរាប់រឿង "ល្ខោន" របស់ព្រះជាម្ចាស់ ។ បើសិនជាយើងនៅតែគិតស្រមៃដល់រឿងល្ខោន ការនោះគឺជា "ផ្ទាំងរាំងននរូបភាព" ចងនៅខាងក្នុងឆាកនៃរោងល្ខោន ដើម្បីតុបតែងរឿងនៃការសង្គ្រោះរបស់ព្រះជាម្ចាស់ ការប្រោសឲ្យជា ការអត់ទោសបាប និង ការផ្ដល់ចេស្ដាក្នុងការធ្វើកិច្ចការងារ ។ ការទូលអង្វររបស់យើង រួមចំណែកនៅក្នុងដំណើរការរបស់ព្រះអម្ចាស់ ដែលបង្កើតឲ្យកិច្ចការងាររបស់ ព្រះជាម្ចាស់ឡើងនៅក្នុងចំណោមមនុស្សជារាស្ត្ររបស់ព្រះអង្គ ។ នេះជាឧបករណ៍មួយនៅក្នុងចំណោមឧបករណ៍ទាំងឡាយ ដែលព្រះជាម្ចាស់ប្រើ ដើម្បីបន្ទន់ចិត្តរឹងរូស និង វិញ្ញាណដែលមិនជឿ ដែលព្រះអង្គធ្វើឲ្យដង្កាប់របស់អំពើបាបបានរលាចេញពីគ្នា ។ ការទូលអង្វរដកនូវសេចក្ដីភ័យខ្លាចចេញ និងមានការងារជាអ្នកដកនូវសេចក្ដីឈឺចាប់នៃសោកនាដកម្មដែលបណ្ដាលមកពីផលវិបាកពីធម្មជាតិ វិបត្តិផ្លូវចិត្ត ការខូចចិត្ត អារម្មណ៍ធុញថប់ បាត់បង់ទំនាក់ទំនងល្អ ជាដើម ។ល។ ការទូលអង្វរនេះគឺជារបាំងយ៉ាងរឹងមាំការពារនឹងបញ្ហាទាំងឡាយនោះឯង ។

ដូច្នេះការអធិស្ឋានទូលអង្វររបស់យើង គឺជាការធ្វើឡើងដោយសេចក្ដីស្រឡាញ់ដ៏សមើ្បម ។ នៅពេលដែលយើងចូលរួមព័ន្ធកិច្ចជា

សង្ឃ ដែលមានតួនាទីជាអ្នកធ្វើការទូលអង្វរនោះ យើងមានការងារអ្នកលាបប្រេងកូឡា ខាងឯវិញ្ញាណ ដោយដួងចិត្តសុខភាព ជួយបន្ធូរការឈឺចាប់ លាបក្រមួន ដែលអាចព្យាបាលឲ្យជាដល់ដួងចិត្ត គំនិត រូបកាយ ព្រលឹង វិញ្ញាណរបស់មនុស្ស ដែលកំពុងទទួលរងនូវការខ្វះខាត ។